# វេទិការៀនសូត្រស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុលើកទី ២៦

# អនុលោមភាពស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

*ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០២០*

*ម៉ោង ៩ :៣០ ដល់ ១២:០០ ព្រឹក*

*តាមរយៈប្រព័ន្ធអនឡាញ* ***Google Meet***

## I. សេចក្តីផ្តើម

ដើម្បីឆ្លើយតបនឹងតម្រូវការរបស់សហគមន៍អង្គការមិនមែនរដ្ឋាភិបាល និងដើម្បីចូលរួមចំណែកទប់ស្កាត់នៃការរីករាលដាលនៃជម្ងឺកូវីដ ១៩ តាមរយៈការអនុវត្តវិធានការណ៍ និងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា អង្គការ គសក នឹងរៀបចំវេទិការៀនសូត្រស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុលើកទី២៦ តាមប្រព័ន្ធអនឡាញ (Google Meet) ក្រោមប្រធានបទ “ **អនុលោមភាពស្តង់ដាររបាយការណ៍ហរិញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ**” ។

ត្រឹមខែធ្នូ ឆ្នាំ២០១៩ អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គសក) មានសមាជិកសរុបទាំងអស់ចំនួន ២០៨ស្ថាប័ន ទាំងអង្គការក្នុងស្រុក និងអង្គការបរទេស ដែលធ្វើការលើវិស័យអភិវឌ្ឍន៍ផ្សេងៗគ្នា និងជាវេទិកាសមាជិកមួយធំជាងគេបំផុត សម្រាប់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា។

## II. គោលបំណងនៃវេទិការៀនសូត្រ

អ្នកចូលរួម នឹងបង្កើនការយល់ដឹងពី

- ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងពិន័យអន្តរការណ៍
- ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ (មូលដ្ឋានសាច់ប្រាក់ និងមូលដ្ឋានគណនីបង្គរ) និងបច្ចុប្បន្នភាពនានាជុំវិញអនុលោមភាពនៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។

## III. អ្នកចូលរួមគោលដៅ

វេទិកានេះ ត្រូវបានរៀបចំឡើងសម្រាប់ **អ្នកជំនាញវិជ្ជាជីវៈ និងអ្នកប្រតិបត្តិការគ្រប់គ្រងហិរញ្ញវត្ថុ** ដែលអញ្ជើញមកពី **សមាគម និងអង្គការមិនមែនរដ្ឋាភិបាល** ក្នុងប្រទេសកម្ពុជា។



DRAFT

## IV. របៀបចុះឈ្មោះ

អ្នកចូលរួមទាំងអស់តម្រូវឲ្យចុះឈ្មោះជាមុន ដើម្បីទទួលបានតំណថ្មី (New Link) ពីក្រុមការងារ អង្គការ គ.ស.ក ក្នុងការចូលរួមវេទិការៀនសូត្រនេះ។

## V. របៀបវារៈ

| ម៉ោង | មាតិកា | អ្នកសម្របសម្រួល |
|---|---|---|
| ០៩:២០-០៩:៣០ | ការចុះឈ្មោះអ្នកចូលរួម | ក្រុមការងារ គសក |
| ០៩:៣០-០៩:៤០ | កិច្ចស្វាគមន៍ និងគោលបំណងវេទិការៀនសូត្រ<br>មតិស្វាគមន៍ពី **លោក ស៊ិន សុខដុម** ប្រធានផ្នែកប្រតិបត្តិការ នៃអង្គការ គ.ស.ក | **លោក សុខ ណេង**<br>អ្នកឯកទេសផ្នែកសិក្សារៀនសូត្រ អង្គការ គ.ស.ក |
| ០៩:៤០-០៩:៥០ | ការណែនាំពីរបៀបប្រើ Google Meet និងបទបញ្ញត្តិក្នុងវគ្គ | |
| ០៩:៥០-១០:២០ | បទបង្ហាញខ្លីអំពីសារៈតានៃអនុលោមភាព និងទំនាក់ទំនងរវាងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធនឹងអនុលោមភាពនៃច្បាប់រួមមាន៖ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ Tire 1 and Tire 2) និងលទ្ធភាពដែលនឹងដាក់ឲ្យអនុវត្តសារជាថ្មីនៅពេលអនាគត | **មន្ត្រីជំនាញពី**<br>ក្រុមប្រឹក្សាជាតិគណនេយ្យ (NAC) |
| ១០:២០-១០:៥០ | បទបង្ហាញខ្លីពីអនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម | |
| ១០:៥០-១១:៥០ | សំណួរ និង ចម្លើយ | **សម្របសម្រួលដោយ៖**<br>**លោក យឿង សុធារ៉ា** ប្រធានផ្នែកកសាងភាពជាដៃគូ បណ្តាញ និងតស៊ូមតិ នៃអង្គការ គ.ស.ក |

DRAFT



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

| | | |
|---|---|---|
| ១១:៥០-១២:០០ | បូកសរុប និង កម្មវិធីបិទ | **តំណាងក្រុមការងារគ្រប់គ្រងហិរញ្ញវត្ថុ អង្គការ គ.ស.ក** |

***<u>កំណត់សម្គាល់:</u>*** *អង្គការ គសក សូមរក្សាសិទ្ធិផ្លាស់ប្តូរ ឬ កែប្រែ របៀបវារៈនៃកម្មវិធីក្នុងករណីចាំបាច់។*

DRAFT



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

Accountability GPP Symbol of Trust 05/10/2018 04/10/2021